**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**National Religious King**

# កិច្ចព្រមព្រៀងរវាង

**កម្មករនិយោជិតនៃរោងចក្រ តៃខា (ខេមបូឌា) ខបភើរេសិន** តំណាងដោយ ប្រតិភូបុគ្គលិក **និង ក្រុមហ៊ុន តៃខា (ខេមបូឌា) ខបភើរេសិន** ដែលមានបណ្ណពន្ធប៉ាតង់លេខ L001-10018886 ដែលមានអាស័យដ្ឋានតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ផ្លូវជាតិលេខ 4 សង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ តំណាងដោយ លោក **NOBUO KOBAYASHI** កាន់លិខិតឆ្លងដែនលេខៈ TS393119 ស្តីពីការព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតមួយចំនួន ដោយបែងចែកជា ៤ ដំណាក់កាល ដោយក្រុមហ៊ុន រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ នៃវិបត្តជំងឺកូវិដ-19 ។

## ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម

**ប្រការ១** កម្មករនិយោជិត យល់ព្រមអោយរោងចក្រ ធ្វើការព្យួកិច្ចសន្យាការងារចំពោះកម្មករនិយោជិតមួយចំនួន ដោយបែងចែកជា ៤ ដំណាក់កាល ដូចខាងក្រោម ៖

- ដំណាក់កាលទី១ ៖ ចំនួន ៧៣នាក់ ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។
- ដំណាក់កាលទី២ ៖ ចំនួន ៦៣នាក់ ចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។
- ដំណាក់កាលទី៣ ៖ ចំនួន ៦២នាក់ ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០
- ដំណាក់កាលទី៤ ៖ ចំនួន ៦៤នាក់ ចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

**ប្រការ២** កម្មករនិយោជិត យល់ព្រមអោយក្រុមហ៊ុនផ្តល់ឧបត្ថម្ភសំរាប់កម្មករនិយោជិតម្នាក់ៗ ក្នុងអំឡុងពេលព្យួរកិច្ចការងារ ដោយយោងទៅតាមសេចក្តីណែនាំលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ស ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវិដ-១៩ ។

**ប្រការ៣** កម្មករនិយោជិត យល់ព្រមអោយក្រុមហ៊ុន ធ្វើការស្នើសុំមកបំពេញការងាជាធម្មតាមកវិញ ក្នុងករណីក្រុមហ៊ុនទទួលបានការបញ្ជាទិញមកវិញ ព្រមទាំងទូទាត់ប្រាក់ជាក់ស្តែងតាមចំនួនថ្ងៃធ្វើការដែលបានត្រលប់មកបំពេញកិច្ចការងារវិញ។

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃដែលភាគីទាំងពីរបានផ្តិតមេដៃស្តាំទុកជាភស្តុតាងលើកិច្ចសន្យានេះតទៅ ។

ថ្ងៃ សុក្រ ០៣កើត ខែពិសាខ ឆ្នាំជូត ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២០

ស្នាមមេដៃស្តាំតំណាងប្រតិភូបុគ្គលិក

ប្រាក់ ម៉ូលីពង្ស    ផឹង សុណា

តំណាងក្រុមហ៊ុន

NOBUO KOBAYASHI